ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

"ទូទាត់នៅក្រៅប្រទេស និងឈ្នះរង្វាន់ទឹកប្រាក់ត្រឡប់មកវិញសរុប ២,០០០ ដុល្លារប្រចាំខែ ជាមួយអ៊ីអនកាត"

បញ្ជាក្តី និងលក្ខខណ្ឌ

និយមន័យ៖

- **កម្មវិធីប្រូម៉ូសិន៖** សំដៅលើកម្មវិធី "ទូទាត់នៅក្រៅប្រទេស និងឈ្នះរង្វាន់ទឹកប្រាក់ត្រឡប់មកវិញសរុប ២,០០០ ដុល្លារប្រចាំខែ ជាមួយអ៊ីអនកាត" ដែលរៀបចំដោយ អ៊ីអន អេសភីប៊ី ស្របតាមលក្ខខណ្ឌដែលបានកំណត់នាពេលនេះ។
- **អ៊ីអន អេសភីប៊ី៖** សំដៅទៅលើ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី។
- **ម្ចាស់កាតដែលមានសិទ្ធិ៖** សំដៅលើម្ចាស់អ៊ីអនកាតទាំងអស់ លើកលែងតែបុគ្គលិករបស់ អ៊ីអន អេសភីប៊ី និងបុគ្គលិកក្រុមហ៊ុនក្នុងសម្ព័ន្ធ អ៊ីអន ដែលកាន់អ៊ីអនកាត និងធ្វើប្រតិបត្តិការដែលមានសិទ្ធិក្នុងអំឡុងពេលប្រូម៉ូសិន។ មិនរាប់បញ្ចូលម្ចាស់អ៊ីអនកាតដែលគណនីកាតរបស់ខ្លួនត្រូវបានផ្អាក បិទ ឬបញ្ចប់សុពលភាពដោយមូលហេតុណាមួយក្នុងអំឡុងពេលប្រូម៉ូសិនឡើយ។
- **ទីតាំងដែលមានសិទ្ធិ៖** សំដៅលើគ្រប់ទីតាំងអាជីវកម្ម និងហាងទំនិញទាំងអស់នៅក្រៅប្រទេស ដែលទទួលការទូទាត់ដោយផ្ទាល់ (Face-to-Face) តាមរយៈអ៊ីអនកាត។
- **អ្នកឈ្នះរង្វាន់៖** សំដៅលើម្ចាស់អ៊ីអនកាតដែលបានបំពេញតាមលក្ខខណ្ឌទាំងអស់ ដែលត្រូវបានកំណត់ ហើយត្រូវបានជ្រើសរើសតាមរយៈប្រព័ន្ធចាប់ឆ្នោតអេឡិចត្រូនិក។

រយៈពេលប្រូម៉ូសិន៖

កម្មវិធីប្រូម៉ូសិននេះចាប់ផ្តើមពីថ្ងៃទី**០១ ខែវិច្ឆិកា ឆ្នាំ២០២៦ ដល់ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៧ («រយៈពេលប្រូម៉ូសិន»)** រួមទាំងថ្ងៃបុណ្យជាតិផងដែរ ឬអាចត្រូវបានបន្ត កែប្រែ ផ្អាក ឬបញ្ចប់ តាមការសម្រេចចិត្តតែមួយគត់ និងដាច់ខាតរបស់ អ៊ីអន អេសភីប៊ី ដោយមិនបាច់ជូនដំណឹងជាមុនឡើយ។

ព័ត៌មានលម្អិតអំពីការផ្តល់ជូន៖

- រយៈពេលប្រតិបត្តិការដែលមានសិទ្ធិគឺ ចាប់ពី ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៦ ដល់ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៧។
- អ៊ីអនកាតដែលមានសិទ្ធិរួមមាន អ៊ីអន វ៉ាយអូឡែតកាត និង អ៊ីអន ហ្គោលកាត ។
- ទីតាំងដែលមានសិទ្ធិគឺហាងទំនិញ ឬអាជីវកម្មទាំងអស់នៅក្រៅប្រទេសដែលទទួលការទូទាត់ដោយផ្ទាល់ (Face-to-Face) តាមរយៈអ៊ីអនកាតប៉ុណ្ណោះ។
- រាល់ប្រតិបត្តិការទូទាត់ដែលមានសិទ្ធិចូលរួមចាប់ពី USD ៣០ ឡើងទៅក្នុងមួយប្រតិបត្តិការ នឹងទទួលបានឱកាសចាប់ឆ្នោតផ្សងសំណាងចំនួន ១ ដង។
- ការធ្វើប្រតិបត្តិការទូទាត់ដែលមានសិទ្ធិចូលរួមច្រើនដង នឹងទទួលបានឱកាសចាប់ឆ្នោតផ្សងសំណាងច្រើនដង ផ្អែកលើចំនួនប្រតិបត្តិការទូទាត់ដែលគ្រប់លក្ខខណ្ឌ។
- **សរុបអ្នកឈ្នះរង្វាន់ចំនួន ៥៥ រូប និងទឹកប្រាក់ ២,០០០ ដុល្លារ ក្នុងមួយខែ ដោយរួមមាន៖**
  - អ្នកឈ្នះរង្វាន់ ៥ នាក់ x ១០០ ដុល្លារ = ៥០០ ដុល្លារ
  - អ្នកឈ្នះរង្វាន់ ១០ នាក់ x ៥០ ដុល្លារ = ៥០០ ដុល្លារ
  - អ្នកឈ្នះរង្វាន់ ២០ នាក់ x ៣០ ដុល្លារ =៦០០ ដុល្លារ
  - អ្នកឈ្នះរង្វាន់ ២០ នាក់ x ២០ ដុល្លារ =៤០០ ដុល្លារ
- ការចាប់ឆ្នោតផ្សងសំណាងនឹងធ្វើឡើងតាមរយៈប្រព័ន្ធចាប់ឆ្នោតអេឡិចត្រូនិករបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី។

កាលវិភាគនៃការចាប់ឆ្នោតប្រចាំខែ និងរង្វាន់ទឹកប្រាក់ត្រឡប់មកវិញ៖

ការចាប់ឆ្នោត	រយៈពេលប្រតិបត្តិការទូទាត់ដែលមានសិទ្ធិចូលរួម	កាលវិភាគចាប់ឆ្នោត	ចំនួនអ្នកឈ្នះ	រង្វាន់ទឹកប្រាក់ត្រឡប់មកវិញ ក្នុងម្នាក់	រង្វាន់ទឹកប្រាក់ត្រឡប់មកវិញ សរុប
លើកទី ១	ចាប់ពីថ្ងៃទី០១ – ៣០ ខែវិច្ឆិកា ឆ្នាំ២០២៦	សប្តាហ៍ទី ២ នៃខែធ្នូ ឆ្នាំ ២០២៦	៥ នាក់	១០០ ដុល្លារ	៥០០ ដុល្លារ
			១០ នាក់	៥០ ដុល្លារ	៥០០ ដុល្លារ
			២០នាក់	៣០ ដុល្លារ	៦០០ ដុល្លារ
			២០នាក់	២០ ដុល្លារ	៤០០ ដុល្លារ
លើកទី ២	ចាប់ពីថ្ងៃទី០១ – ៣១ ខែធ្នូ ឆ្នាំ២០២៦	សប្តាហ៍ទី ២ នៃខែមករា ឆ្នាំ២០២៧	៥ នាក់	១០០ ដុល្លារ	៥០០ ដុល្លារ
			១០ នាក់	៥០ ដុល្លារ	៥០០ ដុល្លារ
			២០នាក់	៣០ ដុល្លារ	៦០០ ដុល្លារ
			២០នាក់	២០ ដុល្លារ	៤០០ ដុល្លារ
លើកទី ៣	ចាប់ពីថ្ងៃទី០១ – ៣១ ខែមករា ឆ្នាំ២០២៧	សប្តាហ៍ទី ២ នៃខែកុម្ភៈ ឆ្នាំ ២០២៧	៥ នាក់	១០០ ដុល្លារ	៥០០ ដុល្លារ
			១០ នាក់	៥០ ដុល្លារ	៥០០ ដុល្លារ
			២០នាក់	៣០ ដុល្លារ	៦០០ ដុល្លារ
			២០នាក់	២០ ដុល្លារ	៤០០ ដុល្លារ

<u>លក្ខខណ្ឌប្រូម៉ូសិន៖</u>

- រាល់ប្រតិបត្តិការទិញទំនិញនៅទីតាំងផ្ទាល់នៅក្រៅប្រទេស ដែលមានទឹកប្រាក់ចាប់ពី ៣០ ដុល្លារអាមេរិកឡើងទៅក្នុងមួយប្រតិបត្តិការ និងទទួលបានឱកាសចាប់ឆ្នោតផ្សងសំណាងចំនួន ១ ដង។
- កម្មវិធីប្រូម៉ូសិននេះអនុវត្តចំពោះការទូទាត់ទំនិញ ឬសេវាកម្មដោយផ្ទាល់ (Face-to-Face) នៅក្រៅប្រទេសដែលគ្រប់លក្ខខណ្ឌដោយប្រើប្រាស់អ៊ីអនកាត។ ប្រតិបត្តិការតាមអនឡាញ (Online) និងពាណិជ្ជកម្មអេឡិចត្រូនិក (E-commerce) មិនមានសិទ្ធិចូលរួមឡើយ។
- ម្ចាស់អ៊ីអនកាតដែលមានសិទ្ធិចូលរួមម្នាក់ៗ អាចឈ្នះរង្វាន់បានតែ ១ លើកប៉ុណ្ណោះ ក្នុងអំឡុងពេលប្រូម៉ូសិនទាំងមូល។ ម្ចាស់អ៊ីអនកាតដែលបានឈ្នះរង្វាន់រួចហើយ នឹងមិនមានសិទ្ធិចូលរួមក្នុងការចាប់ឆ្នោតផ្សងសំណាងលើកបន្ទាប់ទៀតឡើយ។
  ការចំណាយរបស់ម្ចាស់អ៊ីអនកាតរង នឹងត្រូវរាប់បញ្ចូលជាមួយសិទ្ធិចាប់ឆ្នោតផ្សងសំណាងរបស់ម្ចាស់អ៊ីអនកាតដើម ហើយរង្វាន់ទឹកប្រាក់ត្រឡប់មកវិញ នឹងត្រូវបញ្ចូលទៅក្នុងគណនីរបស់ម្ចាស់អ៊ីអនកាតដើម។
- រង្វាន់ទឹកប្រាក់ត្រឡប់មកវិញ នឹងត្រូវបញ្ចូលទៅក្នុងគណនីរបស់ម្ចាស់អ៊ីអនកាតដើម ក្នុងរយៈពេល ៥ ថ្ងៃធ្វើការ បន្ទាប់ពីការប្រកាសឈ្មោះអ្នកឈ្នះរង្វាន់។
- ការចាប់ឆ្នោតផ្សងសំណាងនឹងត្រូវធ្វើឡើងតាមរយៈប្រព័ន្ធចាប់ឆ្នោតផ្សងសំណាងអេឡិចត្រូនិក ចំនួន ៣ លើក (១ លើកសម្រាប់កាលបរិច្ឆេទប្រតិបត្តិការប្រចាំខែនីមួយៗ) ស្របតាមកាលវិភាគខាងលើ។
- អ្នកឈ្នះរង្វាន់នឹងត្រូវប្រកាសនៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី។
- អ្នកឈ្នះរង្វាន់ត្រូវបានស្នើសុំឱ្យចូលរួមក្នុងពិធីប្រគល់រង្វាន់តាមកាលវិភាគដែលបានកំណត់ដោយ អ៊ីអន អេសភីប៊ី។ ក្នុងករណីអ្នកឈ្នះរង្វាន់មិនអាចចូលរួមបាន អ៊ីអន អេសភីប៊ី អាចពិចារណារៀបចំជម្រើសផ្សេងៗជាករណីនីមួយៗ។
- បុគ្គលិកទាំងអស់របស់ អ៊ីអន អេសភីប៊ី និងបុគ្គលិកក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន អ៊ីអន មិនមានសិទ្ធិចូលរួមក្នុងកម្មវិធីចាប់ឆ្នោតផ្សងសំណាងនេះឡើយ។
- រង្វាន់ទឹកប្រាក់ត្រឡប់មកវិញមិនអាចប្តូរជាសាច់ប្រាក់ ឬទំនិញ សេវាកម្មផ្សេងទៀតបានឡើយ។
- អ៊ីអន អេសភីប៊ី រក្សាសិទ្ធិក្នុងការកែប្រែ ផ្អាក ឬបញ្ចប់កម្មវិធីប្រូម៉ូសិននេះ ស្របតាមលក្ខខណ្ឌ និងតម្រូវការពាក់ព័ន្ធដោយមិនចាំបាច់ជូនដំណឹងជាមុន។

<u>ការដកសិទ្ធិ៖</u>

អ៊ីអន អេសភីប៊ី រក្សាសិទ្ធិផ្តាច់មុខក្នុងការដកសិទ្ធិចូលរួមរបស់ម្ចាស់កាតដែលមានសិទ្ធិណាមួយ ដោយមិនចាំបាច់ជូនដំណឹងជាមុនក្នុងករណី៖

(ក) គណនីរបស់ម្ចាស់កាតដែលមានសិទ្ធិស្ថិតនៅក្នុងលំនាំដើម (ព័ត៌មានលម្អិតនៃ "លំនាំដើម" សូមចុចលើតំណភ្ជាប់ TCs-AEONCARD-EN & TCs-AEONCARD-KH) ក្នុងអំឡុងពេលប្រូម៉ូសិន ឬ

(ខ) គណនីរបស់ម្ចាស់កាតដែលមានសិទ្ធិត្រូវបានបិទក្នុងអំឡុងពេលប្រូម៉ូសិន ឬ

(គ) ម្ចាស់កាតដែលមានសិទ្ធិបានផ្តល់ព័ត៌មានមិនពិត ឬប្រព្រឹត្តបទល្មើសក្នុងរបៀបណាមួយក្នុងអំឡុងពេលប្រូម៉ូសិន ឬ

(ឃ) ម្ចាស់កាតដែលមានសិទ្ធិបានរំលោភលើលក្ខខណ្ឌណាមួយដែលមានចែងនៅទីនេះ។

<u>ការទទួលខុសត្រូវ៖</u>

អ៊ីអន អេសភីប៊ី នឹងមិនទទួលខុសត្រូវចំពោះអ្នកចូលរួមចំពោះការខូចខាតណាមួយដែលមានលក្ខណៈ ឬការខាតបង់ណាមួយដែលទទួលរង (រួមទាំងប៉ុន្តែមិនកំណត់ចំពោះការបាត់បង់ឆន្ទៈល្អ ប្រាក់ចំណូល ឬប្រាក់ចំណេញ ឬជាលទ្ធផល ដោយផ្ទាល់ ឬដោយប្រយោល គំរូ ចៃដន្យ ផ្តន្ទាទោស ឬការខូចខាតពិសេស) ទោះបីជាកើតឡើងទាក់ទងនឹងការចូលរួមក្នុងប្រូម៉ូសិន ឬអ៊ីអន អេសភីប៊ី អនុវត្តសិទ្ធិរបស់ខ្លួនដោយអនុលោមតាមលក្ខខណ្ឌណាមួយនៅទីនេះ។

<u>ខចែងផ្សេងទៀត៖</u>

(ក) ការសម្រេចរបស់ អ៊ីអន អេសភីប៊ី លើរាល់បញ្ហាដែលពាក់ព័ន្ធនឹងប្រូម៉ូសិននេះគឺការចងកាតព្វកិច្ច និងការសម្រេចជាចុងក្រោយ ហើយនឹងមិនមានការឆ្លើយឆ្លងបន្ថែមដើម្បីកែប្រែ ឬការកែប្រែពីភាគីដទៃទៀតនោះទេ។ រាល់លក្ខខណ្ឌដែលមានចែងនៅទីនេះត្រូវបានគ្រប់គ្រង និងបកស្រាយដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។

(ខ) អ្នកចូលរួមទាំងអស់បានអាន និងយល់ពីរាល់លក្ខខណ្ឌដែលបានបញ្ជាក់នៅទីនេះ ហើយ អ៊ីអន អេសភីប៊ី មានសិទ្ធិផ្តាច់មុខក្នុងការផ្អាក បញ្ចប់ ឬលុបចោលប្រូម៉ូសិននៅពេលណាមួយដោយគ្មានហេតុផល និងដោយមិនចាំបាច់ជូនដំណឹងជាមុនទៅអតិថិជនដូចដែលបានបញ្ជាក់នៅលើគេហទំព័រ អ៊ីអន អេសភីប៊ី www.aeon.com.kh

(គ) សម្រាប់ការណែនាំ និង/ឬមតិយោបល់ពាក់ព័ន្ធនឹងប្រូម៉ូសិននេះ សូមទាក់ទងមកកាន់លេខទូរស័ព្ទទាន់ហេតុការណ៍របស់ អ៊ីអន អេសភីប៊ី តាមរយៈទូរស័ព្ទទៅលេខ ០២៣/០៧០/០៧៨ ៩៨៨ ៥៥៥។